00420959

E169/1/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour Suprême

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 001/18-07-2007-ECCC/SC

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / 12 / 2009
ម៉ោង (Time/Heure): 11:02
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

ចំពោះមុខ: **ចៅក្រម គង់ ស្រ៊ិម** **ប្រធាន**
**ចៅក្រម Motoo NOGUCHI**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Agnieska KLONOWIECKA-MILART**
**ចៅក្រម ស៊ិន រិទ្ធ**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម យ៉ា ណារិន**

កាលបរិច្ឆេទ: ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

ឯកសារបានចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 28 / 12 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

---

# សេចក្តីសម្រេចលើបណ្តឹងសាទុក្ខដែលបានដាក់ដោយមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម២ និង ក្រុម៣ ប្រឆាំងនឹងសេចក្តីសម្រេចធ្វើឡើង ដោយផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩

---

<u>ម្ចាស់បណ្តឹងសាទុក្ខ-មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី(ក្រុម២ និង ក្រុម៣)</u>

គឹម ម៉េងឃី
គង់ ពិសី
មុំច សុវណ្ណារី
ហុង គឹមសួន

<u>ជនជាប់ចោទ</u>

កាំង ហ្គេក អ៊ាវ ហៅ ឌុច

E169/1/2

Martine JACQUIN
Annie DELAHAIE
Philippe CANONNE
Elizabeth RABESANDRATANA
Fabienne TRUSSES-NAPROUS
Christine MARTINEAU

យុង ផានិត
Silke STUDZINSKY

**មេធាវីជនជាប់ចោទ**

ការ សាវុត្ថ
François ROUX
Marie-Paul CANIZARÈS

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម១ និងក្រុម៤)**

ទី ស្រីនណា
Piere Olivier SUR
Alain WERNER
Brianne McGONIGLE
Karim KHAN

**សហព្រះរាជអាជ្ញា**

ជា លាង
William SMITH(ស្តីទី)

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”)

## I. **ប្រវត្តិនីតិវិធី និង សារណារបស់ភាគី**

**១.អង្គជំនុំជម្រះតុលាការកំពូល** បានទទួលបណ្តឹងសាទុក្ខចំនួនពីរ ដែលបានដាក់ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ២ និង ក្រុម៣ ប្រឆាំងនឹងសេចក្តីសម្រេចដោយផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ (“បណ្តឹងសាទុក្ខ”)។

២. អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចពីរដោយផ្ទាល់មាត់នៅថ្ងៃទី២៧ ខែ សីហា ឆ្នាំ២០០៩ ដោយសំលេងភាគច្រើន លើកលែងមតិជំទាស់ពីចៅក្រម **Jean-Mare LAVERGNE** ថា ដើមបណ្តឹងរដ្ឋប្បវេណីនឹងមិនត្រូវបានអនុញ្ញាតឲ្យធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងតាំងសំណួរដល់សាក្សី និង ដល់ កាំង ហ្កេកអ៊ាវ ហៅ “ឌុច” (“ជនជាប់ចោទ”) ដែលសំណួរទាំងនោះពាក់ព័ន្ធទៅនឹង អត្តចរិតរបស់ជនជាប់ចោទ (សេចក្តីសម្រេចទាំងនោះរួមមាន “សេចក្តីសម្រេចលើសេចក្តីសន្និដ្ឋានផ្តន្ទាទោសជនជាប់ចោទ” និង “សេចក្តីសម្រេចលើការសួរសំណួរពាក់ព័ន្ធទៅនឹងអត្តចរិតរបស់ជនជាប់ចោទ ”)។[1]

៣. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ បានដាក់ការជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេច លើការសួរសំណួរពាក់ព័ន្ធទៅនឹងអត្តចរិតរបស់ជនជាប់ចោទ នៅថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០៩។[2] នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ បានដាក់សារណា ដោយលើកឡើងនូវទឡ្ហីករណ៍ថា សេចក្តីសម្រេចមិនអនុញ្ញាតឲ្យតំណាងដើមបណ្តឹងរដ្ឋប្បវេណី សួរសំណួរទាក់ទិនទៅនឹងអត្តចរិតរបស់ជនជាប់ចោទ បានធ្វើឲ្យមានលក្ខណៈខុសគ្នារវាងដើមបណ្តឹងរដ្ឋប្បវេណី និងភាគីដទៃទៀត ។[3]

---

[1] សវនាការជំនុំជម្រះ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩,T. ៤២. ៧៤

[2] CPG 3: ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ “សេចក្តីជូនតំណឹងអំពីបណ្តឹងសារទុក្ខ” សំណៅដើមជាភាសាបារាំង និងខ្មែរ ដែលបានដាក់នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩ (ឯកសារ E162)។

[3] “CPG3: ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ “សារណាបណ្តឹងសារទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩” សំណៅដើមជាភាសាបារាំង និងខ្មែរ ដែលបានដាក់កាលពីថ្ងៃទី០២



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME * C.C.C * C.E.T.C *

**៤.** សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី(ក្រុម ២) បានដាក់សារណាបណ្តឹងសាទុក្ខនៅថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០០៩ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង និងបានដាក់សារណាបន្ថែមនៃបណ្តឹងសាទុក្ខនៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៩ ដោយបានលើកនូវទឡ្ហីករណ៍ថា បណ្តឹងសាទុក្ខរបស់ពួកគាត់អាចទទួលយកបាន ដោយអនុលោមទៅតាមវិធាន ១០៤(៤)(ង) នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក ហើយនិងថា សេចក្តីសម្រេចលើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងលើការសួរសំណួរពាក់ព័ន្ធទៅនឹងអត្តចរិតរបស់ជនជាប់ចោទ មានលក្ខណៈភន្តច្រឡំនៃអង្គច្បាប់។[4]

**៥.** ទឡ្ហីករណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ និង ក្រុម៣ ទៅលើអង្គសេចក្តី មិនត្រូវបានលើកយកមកបង្ហាញនៅទីនេះទេ ដោយសារសំអាងហេតុដូចបានលើកឡើងនៅខាងក្រោម។

**៦.** អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនៅថ្ងៃទី ១២ ខែ តុលា ឆ្នាំ២០០៩ ដោយបានបញ្ជាក់យ៉ាងលំអិតនូវសំអាងហេតុទាំងមតិភាគច្រើន និង មតិជំទាស់របស់ចៅក្រម **Jean-Mare LAVERGNE** ទាក់ទិនទៅនឹងសេចក្តីសម្រេច លើការសួរសំណួរពាក់ព័ន្ធទៅនឹងអត្តចរិតរបស់ជនជាប់ចោទ និងសេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោសទៅលើជនជាប់ចោទ។[5]

---

ខែកញ្ញា ឆ្នាំ២០០៩ (ឯកសារ E162/2) ដោយភ្ជាប់មកជាឧបសម្ព័ន្ធ ការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជិន ម៉េត និង អ៊ុក វ៉ាសុផិន ដើម្បីដាក់បណ្តឹងសាទុក្ខនេះ តាមរយៈវិធាន១០៦(៤) នៃវិធានផ្ទៃក្នុង អ.វ.ត.ក(ឯកសារ E162/2.1)។

[4] "បណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី(ក្រុម ២) ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង មិនអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីសួរសំណួរជនជាប់ចោទ សាក្សី និង អ្នកជំនាញស្តីពីអត្តចរិត របស់ជនជាប់ចោទ និង មិនអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណី ធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស", ច្បាប់ដើមជាភាសាអង់គ្លេសនិងភាសាខ្មែរ ដែលត្រូវបានគេដាក់នៅថ្ងៃទី ២៥ ខែ កញ្ញា ២០០៩ (ឯកសារ E169 ភ្ជាប់ជាមួយនឹងឧបសម្ពន្ធ័ E169.1 ដល់ E169.5).។

[5] "សេចក្តីសម្រេចលើសំណើសុំរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី លើការសម្រេចអំពីសិទ្ធិរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោសនិងសេចក្តីណែនាំទាក់ទងនឹងការសួរសំនួរ



SUPREME COURT CHAMBER E.C.C.C * C.E.T.C.

00420963



៧. ឯកសារទាក់ទិនទៅនឹងបណ្តឹងសាទុក្ខទាំងពីរនេះ ត្រូវបានបញ្ជូនទៅអង្គជំនុំជម្រះតុលាការកំពូល នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៩ និងថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៩ ដោយអនុលោមតាមវិធាន ១០៨(២) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។[6]

## II. សំអាងហេតុ

៨. អង្គជំនុំជម្រះតុលាការកំពូលអាចសម្រេចទៅលើបណ្តឹងសារទុក្ខភ្លាមៗ ដោយផ្អែកតែទៅលើសារណាជាលាយលក្ខណ៍អក្សរ អនុលោមតាមវិធាន ១០៩(១) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

៩. យុត្តាធិការនៃអង្គជំនុំជម្រះតុលាការកំពូល ត្រូវបានកំណត់ដោយវិធាន ១០៤ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក អនុវិធាន (១) ដែលបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងទៅនឹងសេចក្តីសំរេចរបស់អង្គជំនុំជម្រះសាលាដំបូងអាចធ្វើទៅបានដោយផ្អែកលើមូលដ្ឋាននៃ "ការភ័ន្តច្រឡំដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលនាំអោយប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ"។

១០. វិធាន១០៤(៤) នៃវិធានផ្ទៃក្នុង អ.វ.ត.ក បានកម្រិតបន្ថែមទៀតលើបណ្តឹងសាទុក្ខភ្លាមៗចំពោះសេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូងដូចខាងក្រោម៖

ក-សេចក្តីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី ។

ខ-សេចក្តីសម្រេចអំពីការឃុំខ្លួននិងការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការអនុលោម តាមវិធាន ៨២ ។

គ-សេចក្តីសម្រេចអំពីវិធានការការពារតាមវិធាន ២៩(៤)(គ) ។

ឃ-សេចក្តីសម្រេចស្តីពី ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះតាមវិធាន ៣៥(៦) ។ និង

---

ជនជាប់ចោទ អ្នកជំនាញ និង សាក្សីដែលធ្វើសក្ខីកម្មស្តីពីអត្តចរិត", ដាក់នៅថ្ងៃទី ១២ ខែតុលា ឆ្នាំ២០០៩ (ឯកសារ E72/3) ។

[6] "ការចុះបញ្ជីបណ្តឹងសាទុក្ខ(ឯកសារ E162)", ដាក់នៅថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ២០០៩ (ឯកសារ E162/1)។ "ការចុះបញ្ជីបណ្តឹងសាទុក្ខ(ឯកសារ E169)", ដាក់នៅថ្ងៃទី៦ ខែ តុលា ឆ្នាំ ២០០៩ (ឯកសារ E169/1)។



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME E.C.C.C * E.T.C

00420964

០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

E169/1/2

ង-សេចក្តីសម្រេចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងវិធាន ២៣(៤)។

សេចក្តីសម្រេចផ្សេងទៀត អាចប្តឹងសាទុក្ខបានតែក្នុងករណីដែលបានធ្វើឡើងស្របពេលជាមួយគ្នានឹងបណ្តឹងសាទុក្ខពីសាលក្រមលើអង្គសេចក្តី។

១១. ក្រោមវិធាន ២៣(៤) នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក ទាំងសេចក្តីសម្រេចអំពីការសួរសំណួរពាក់ព័ន្ធទៅនឹងអត្តចរិតរបស់ជនជាប់ចោទ និង សេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោសទៅលើជនជាប់ចោទ ពុំអាចត្រូវបានគេបកស្រាយថា ជាការមិនអាចទទួលយកបាននូវការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នោះទេ។

១២. ដូច្នេះ សេចក្តីសម្រេចអំពីការសួរសំណួរពាក់ព័ន្ធទៅនឹងអត្តចរិតរបស់ជនជាប់ចោទ និង សេចក្តីសន្និដ្ឋានអំពីការផ្តន្ទាទោសទៅលើជនជាប់ចោទ ពុំស្ថិតនៅក្នុងវិសាលភាពវិធាន១០៤(៤) នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.កទេ។ ហេតុដូច្នេះហើយ សេចក្តីសម្រេចទាំងនេះ "អាចប្តឹងសាទុក្ខបាន តែក្នុងពេលជាមួយគ្នានឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើអង្គសេចក្តីតែប៉ុណ្ណោះ។"[7]

**យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា** បណ្តឹងសាទុក្ខទាំងពីរនេះពុំអាចទទួលយកបាន ដោយអនុលោមតាមវិធាន១០៤(៤) នៃវិធានផ្ទៃក្នុងអ.វ.ត.ក និង **សម្រេចបដិសេធបណ្តឹងសាទុក្ខនេះ។**

**រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME * E.C.C.C * C.E.T.C *

**គង់ ស្រ៊ឹម**

[7] វិធាន១០៤(៤) នៃវិធានផ្ទៃក្នុង អ.វ.ត.ក។